# ក្រុមហ៊ុន អ៊ិន ហ្វុង(ខេមបូឌា)ហ្គាមិនត៍

INFONG ( CAMBODIA ) GARMENT CO.,LTD


អសយដ្ឋានៈ សួនឧស្សាហកម្មកាណាឌីយ៉ា អគារលេខ6-7 ផ្លូវវេងស្រេង ភូមិត្រពាំងថ្លឹង២ សង្កាត់ចោមចៅ១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ


## កិច្ចប្រជុំព្រមព្រៀង
## ស្តីពី
## ការព្យួរកិច្ចសន្យាការងារក្នុងក្រុមហ៊ុន អ៊ិន ហ្វុង(ខេមបូឌា)ហ្គាមិនត៍

នៅថ្ងៃទី 19 ខែ 04 ឆ្នាំ 2023 វេលាម៉ោង 09 : 30 នាទីព្រឹក។ នៅបន្ទប់ប្រជុំក្រុមហ៊ុន បានប្រជុំពិភាក្សាគ្នាស្តីអំពីការព្យួរកិច្ចសន្យាការងារនៅក្នុងក្រុមហ៊ុន អ៊ិន ហ្វុង(ខេមបូឌា)ហ្គាមិនត៍។ ដែលមានសមាសភាពចូលរួមដូចខាងក្រោមៈ

1-ខាងក្រុមហ៊ុន អ៊ិន ហ្វុង(ខេមបូឌា)ហ្គាមិនត៍។

-Mr. Ma Shunhua នាយកក្រុមហ៊ុន

-Mrs. **ឃួន សុខសាន្ត** ប្រធានរដ្ឋបាល

-Mrs. **ជា មួយជូ** បកប្រែ

2-ខាងតំណាងកម្មករ / តំណាងសហជីព/ប្រធានក្រុម

-Mr.**ឡុញ សំ** តំណាងកម្មករ / តំណាងសហជីពសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា(ស៊ីខៅឌូ)

- Mr. **លី តារា** តំណាងសហម្ព័ន្ធសហជីពកម្មករកម្ពុជា

-គ្រប់ប្រធានក្រុម ប្រធានផ្នែក គ្រប់ក្រុម

ក្រោយពីបានពិភាក្សាយ៉ាងល្អិតល្អន់រួចមក ភាគីខាងក្រុមហ៊ុន នឹង ភាគីតំណាងកម្មករ / តំណាងសហជីព/គ្រប់ប្រធានក្រុម ប្រធានផ្នែក គ្រប់ក្រុមបានព្រមពៀងនឹង ឯកភាពគ្នាទាក់ទងនឹងការរៀបចំព្យួរការងារដូចខាងក្រោម:

១-សំរេចព្យួរការងាររយ:ពេល14ថ្ងៃ។ គឺចាប់ពីថ្ងៃទី01 ខែ05 ឆ្នាំ2023 ដល់ ថ្ងៃទី14 ខែ05 ឆ្នាំ2023 ថ្ងៃទី15 ខែ05 ឆ្នាំ2023 ចូលធ្វើការធម្មតាវិញ។

២-យោងតាមសេចក្តីណែនាំរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវ:លេខ: 020/23 កប/ស,ណ,ន,ខ,ល ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិកធ្វើការនៅរោងចក្រក្នុងវិស័យវាយនភណ្ឌកាត់ដេរ ផលិតស្បែកជើងនិងផលិតផលិតផលធ្វើដំណើរនិងកាបូបដែលរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចសកល។ដូច្នេះបងប្អូនកម្មករនិយោជិកទាំងអស់ដែលត្រូវបានព្យួរកិច្ចសន្យាការងារនៅថ្ងៃទី០១ខែឧសភា ឆ្នាំ២០២៣ នឹងត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួន២០ដុល្លាអាមេរិកពីរាជរដ្ឋាភិបាល និង ១៥ដុល្លាអាមេរិកពីនិយោជកសំរាប់ការព្យួរកិច្ចសន្យាការងាររយ:១៤ថ្ងៃនេះ។

扫描全能王 创建

៣-នៅថ្ងៃទី 10 ខែ05 ឆ្នាំ2023 ក្រុមហ៊ុនរៀបចំបើកប្រាក់ឈ្នួលដែលនៅសល់សំរាប់ ខែ04 ឆ្នាំ2023 ។

៤-កម្មករនិយោជិតដែលត្រូវព្យួរការងារនៅក្នុងក្រុមហ៊ុន អ៊ិន ហ្វុង(ខេមបូឌា)ហ្គាមិនត៍មានចំនួនសរុបទាំងអស់ ៥៥៦នាក់ (ប្រាំរយហាសិបប្រាំមួយនាក់)។

ចុងបញ្ចប់នៃកិច្ចប្រជុំនេះ លោកនាយកក្រុមហ៊ុនបានថ្លែងអំណរគុណចំពោះអ្នកចូលរួមទាំងអស់ ដែលបានចូលរួមពិភាក្សាផ្តល់មតិយោបល់គ្នាទៅវិញទៅមក។

កិច្ចប្រជុំនេះបានបញ្ចប់នៅវេលាម៉ោង 10 : 30 នាទីព្រឹកថ្ងៃខែឆ្នាំដដែល ។

**ប្រធានរដ្ឋបាល ក្រុមហ៊ុន**

Mrs. ឃួន សុខសាន្ត

**តំណាងកម្មករ / តំណាងសហជីព/ប្រធានក្រុម**

បានឃើញ នឹង ឯកភាព

**ប្រធានកិច្ចប្រជុំ**

បានឃើញ នឹង ឯកភាព

扫描全能王 创建